ការចរចា និង នយោបាយ

នយោបាយ ត្រូវស្គាល់បរិធាន សំរាប់ប្រើ, ដូច្នេះ ការចរចា ជាការទូត ដែលតម្រូវ អោយនយជន[1] យកមកប្រើ ជាបរិធាន។ តែ ការចរចា ក៏មិនត្រូវភ្លេចគោលដៅដើម នៃនយោបាយ, ដូចយ៉ាង នៅពេលសង្គ្រាម គឺ នឹកក្នុក ដល់សន្តិភាព បើទោះបី នៅលើសមរភូមិ មានការប្រយុទ្ធដ៏កាចសាហាវ។ នៅក្នុងស្រុកខ្មែរ គ្មានសង្គ្រាម ក៏មិនត្រូវភ្លេចលួចកលខូចយកឈ្នះ របស់ភាគីប្រឆាំង បើទោះបី មានលទ្ធិប្រជាធិបតេយ្យជាគ្រឿងលំអ របប។ របៀបចរចា តាំងពីដើមដំបូងមក របស់គណបក្ស ប្រឆាំង ឬ ភាគីមិមមែនកុម្មុយនិស្ត គឺការកាន់ច្រឡំ រវាងកម្លាំងទ័ព នៃអង្គការសហប្រជាតិ និង កម្លាំងខ្លួនឯងដោយ នឹងស្មានថា គ្រប់ចំណារផ្លូវទូត វាមានពលានុភាពមូល ទៅលើ ភាគីកុម្មុយនិស្ត មានយួនកុម្មុយនិស្ត និង ភាគីភ្នំពេញ។ ដូចគ្នានឹង កិច្ចសន្យា រវាងគណបក្សកាន់អំណាច និង គណបក្សសង្គ្រោះជាតិ នៅឆ្នាំ ២០១៤។ ហើយបច្ចុប្បន្ន អ្នកដឹកនាំគណបក្ស ប្រឆាំង កំពុងយល់ច្រឡំជាថ្នឹថា សម្ពាធអន្តជាតិនឹងអាចមានឫទ្ធានុភាពទោល ទៅលើរបបនៅភ្នំពេញ ហើយនាំគ្នាប្រកាសថា រឫធម៌សន្ទនា នៅមានធរមានជានិច្ច, តែរបៀបចរចាថ្មី វាមិនឃើញមានអ្វី ជាកម្លាំង នៃជញ្ជីងនយោបាយ របស់ខ្លួន ក្រៅតែប្រកាស នូវមាតុភូមិនិវត្តន៍ របស់មេដឹកនាំ៖

---

[1] នយជន : អ្នកនយោបាយ។